ព្រះរាជាណាចក្រកម្ពុជា -143-

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ០២

ចុះថ្ងៃទី០២ ០១ ២០០៣

សាលដីកា

លេខ : ២៦

ចុះថ្ងៃទី០៤ ០៦ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៤ ខែមិថុនាឆ្នាំ២០០៣

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ដឹង រេកង ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥ - លោក ម៉ន សារឿន ចៅក្រម

ក្រឡាបញ្ជី

លោក ឃាង ស៊ឹន

តំណាងអយ្យការ

លោក យួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៤២ "គ" ចុះថ្ងៃទី០៧ ០៨ ២០០២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ០២ ចុះថ្ងៃទី០២ ០១ ២០០៣ របស់តុលាការកំពូល ។

១ - ជនជាប់ចោទឈ្មោះលឹម គឹមសេង "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥១អឺ០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ មុខរបរ លក់នាឡិកា ប្រពន្ធឈ្មោះចៅ សៀង មានកូន ០២ នាក់ ឪពុកឈ្មោះ អ៊ិច តុំ "ស" ម្តាយឈ្មោះលី អ៊ី "រ"

២ - ជនជាប់ចោទឈ្មោះ ចៅ សៀង "ចុងបណ្តឹងសាទុក្ខ" ភេទ ស្រី អាយុ ៣៥ ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ៥១អឺ០ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ប្តីឈ្មោះលឹមគឹម សេង មានកូន០២នាក់ ឪពុកឈ្មោះឈឹង កាន់ "ស" ម្តាយឈ្មោះ អ៊ីវ អេង "ស" ។

- ត្រូវចោទពីបទៈប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃ ២៧ ១២ ២០០១ តាមមាត្រា ០៤ នៃច្បាប់ស្តីពីទោសនៃបទឧក្រិដ្ឋ ។

- មេធាវី លោកកែវ យ៉ា

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះរស់ ចិន្តា "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ស្រី អាយុ៤២ ឆ្នាំ មុខរបរលក់ដូរ សព្វថ្ងៃនៅផ្ទះលេខ១៦៨អឺ២ត្រឹក សង្កាត់អូរឫស្សីទី១ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ។

- មេធាវី គ្មាន

- តាមពាក្យបណ្តឹងចុះថ្ងៃទី២៨ ០១ ២០០២ របស់ឈ្មោះរស់ ចិន្តា ប្តឹងពីឈ្មោះ ទៀ សៀង និងឈ្មោះលឹម គឹមសេង ពីបទប៉ុនប៉ងធ្វើមនុស្សឃាតខ្លួននិងប្តីខ្លួន ទារសំណងជម្ងឺចិត្តចំនួន ៥០.០០០ ដុល្លា ជាថ្នូរដែលជននោះប្រមាថជីវិតខ្លួននិងប្តីខ្លួន ដោយបញ្ជាក់ថា កាលពីថ្ងៃទី ២៧ ១២ ២០០១ វេលាម៉ោង១២ ១០នាទី ឈ្មោះទៀ សៀងនិងឈ្មោះលឹម គឹមសេង បានមកឈ្លោះប្រមាថខ្លួននិងប្តីខ្លួននៅកន្លែងតូបលក់ ។ មិនតែប៉ុណ្ណោះអ្នកទាំងពីរនាក់ប្តីប្រពន្ធនោះ បានទូរស័ព្ទទៅហៅជើងការ៧ទៅ៨នាក់ មកគំរាមប៉ុនប៉ងធ្វើឃាតដល់ខ្លួននិងប្តីខ្លួន ហើយជើងការទាំងនោះនិយាយថា អាណាខ្លាំង អញកំពុងតែរកមុខអង ខ្លួនសុំឱ្យធ្វើការផ្តន្ទាទោសតាមច្បាប់ ។

- បានឃើញលិខិតជូនដំណឹងលេខ ១៥១ រម ចុះថ្ងៃទី១៨ ០៣ ២០០២ របស់តុលាការក្រុងភ្នំពេញ ជំរាបមកលោកស្រី រស់ ចិន្តា អំពីការសុំដីកាចាប់ខ្លួននិងឃុំខ្លួនលើឈ្មោះលឹម គឹមសេង និងប្រពន្ធឈ្មោះទៀ សៀង ពីបទៈ ចោទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនានោះ "សំរេចមិនឃុំខ្លួននិងចាប់ខ្លួនជនល្មើសទាំងពីរខាងលើនេះទេឡើយ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៥ចុះថ្ងៃទី២០ - ០៣ - ២០០២ របស់ឈ្មោះរស់ ចិន្តា តវ៉ាពីការមិនឃុំខ្លួន ចាប់ខ្លួនរបស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា ៖

១ - ទទួលពាក្យបណ្តឹងតវ៉ាលេខ ០៥ ចុះថ្ងៃទី២០ ០៣ ២០០២ របស់ឈ្មោះរស់ ចិន្តា ប្តឹងនឹងការសំរេចមិនឃុំខ្លួន ចាប់ខ្លួនរបស់ចៅក្រម ដែលធ្វើឡើងមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ។ តែបដិសេធការសុំឃុំរបស់រស់ ចិន្តា ចោលដោយទាស់គតិច្បាប់ ។

២ - តំកល់ការសំរេចមិនឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតក្រុងភ្នំពេញ ទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤២ "គ" ចុះថ្ងៃទី០៧ ០៨ ២០០២ របស់ សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ០៣ ២០០២ របស់ឈ្មោះ រស់ ចិន្តា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២ - តំកល់ដីកាមិនឃុំខ្លួន ចុះថ្ងៃទី១៥ - ០៣ - ២០០២ របស់ចៅក្រមស៊ើបអង្កេតលើពាក្យសុំដីកាចាប់ខ្លួននិងឃុំខ្លួនចុះថ្ងៃទី០៧ ០៣ ២០០២ របស់ឈ្មោះរស់ ចិន្តា ទុកជាបានការ ។

៣ - សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ រស់ ចិន្តា មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណោម ស្រី ចំពោះមុខមេធាវីការពារជនជាប់ចោទ លោក ឌី បូរីម៉ា និងលោក ទូត លុច កំបាំងមុខជនជាប់ចោទឈ្មោះទៀ សៀងនិងឈ្មោះលឹមគឹម សេង បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ១៨ចុះថ្ងៃទី២៣ ០៩ ២០០២ របស់ឈ្មោះរស់ ចិន្តា ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៤២ "គ" ចុះថ្ងៃទី០៧ ០៨ ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណារបស់ឈ្មោះ រស់ ចិន្តា ចុះថ្ងៃទី១៧.០១.២០០៣ ។

- បានឃើញសារណាតបរបស់ឈ្មោះលឹម គឹមឈេង និងទៅ សៀង ចុះថ្ងៃទី ២៥-០២-២០០៣ ។

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះលឹម គឹមឈេងនិង ទៅ សៀង ពីបទប៉ុនប៉ងធ្វើឃាតមនុស្សដោយ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៧-១២-២០០១ តាមមាត្រា០៤នៃច្បាប់ស្ថានទំងន់ទោស នៃបទឧក្រិដ្ឋ ។

- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤២ "ត" ចុះថ្ងៃទី០៧.០៨.២០០២ របស់ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្ដាប់សារណារបស់មេធាវីបណ្ដឹងសាទុក្ខអ្នកស្រីរស់ ចិន្តា និង សារណាតបរបស់ ជនជាប់ចោទឈ្មោះលឹម គឹមឈេងនិង ទៅ សៀង ។

- បានស្ដាប់លោក រ៉ែន ឈ៉ា លើកឡើងនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួននៅពេលសវនាការថា: ក្នុងនាមខ្លួនជាមេធាវីការពារអោយជនជាប់ចោទដែលជាកូនក្ដីមានឈ្មោះលឹម គឹមឈេងនិង ទៅ សៀង នោះ សូមបញ្ជាក់ជូនថា.កូនក្ដីរបស់ខ្លួនពិតជាពុំបានប្រព្រឹត្តប៉ុនប៉ងធ្វើឃាតមនុស្សដូចការលើកឡើងតាមសារណារបស់ដើមបណ្ដឹងឡើយ ។ ព្រោះអំពើការទំនាស់នោះកើតឡើងពីដើមបណ្ដឹងដោយមានការជេរប្រមាថមកលើកូនក្ដីខ្លួនមុន តែរឿងនោះក៏ស្ងាត់អស់ហើយព្រោះកូនក្ដីខ្លួនគ្រាន់តែមានមេអ៊ុំ ជាអង្គរក្ស១ ២ នាក់ប៉ុណ្ណោះ ដើម្បីការពារសុវត្ថិភាពក្នុងពេលយកជូន ពុំបានរំរាមកំហែងលើគូភាគីណាមួយឡើយ តែដោយដើមបណ្ដឹងយល់ខុសក៏ប្ដឹងចោទមកលើកូនក្ដីរបស់ខ្លួនថា.ប៉ុនប៉ងធ្វើឃាតមនុស្សទៅវិញ ដូច្នេះបើពិនិត្យមើលលក្ខណភាពនិងគ្រប់សំណុំរឿងទាំងអស់ គ្មានចំណុចណាមួយពាក់ព័ន្ធមកលើកូនក្ដីខ្លួនដែរ ហើយតុលាការថ្នាក់ក្រោមក៏បានសំរេចលើកលែងចោទប្រកាន់ ។ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា: សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកជាបានការដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្ដាប់សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងជនជាប់ចោទព្រមទាំងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

តុលាការកំពូល

- យល់ឃើញថាបណ្ដឹងសាទុក្ខលេខ២៨ចុះថ្ងៃទី២៣.០៨.២០០២របស់អ្នកស្រីរស់ ចិន្តា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី ។

....៤ ....

- យល់ឃើញថាការលើកឡើងរបស់អ្នកស្រីរស់ ចិន្តា ក្នុងសារណាចុះថ្ងៃទី១៧ ០១ ០៣ថា ៖ នៅថ្ងៃទី២៧ ១២ ០១ វេលាម៉ោង១២ ១០នាទីឈ្មោះ សៀងនិងឈ្មោះលីម គឹមសេងជាប្ដីប្រពន្ធ បានចូលមកតូបរបស់ខ្លួននិយាយចៀមដាមជេរប្រមាថអាសអាភាសបំផុតមកលើខ្លួននិងប្ដីខ្លួន សំដែងអាកប្បកិរិយាអុកឡុក ហើយការទូរស័ព្ទទៅពួកជើងកាង៥នាក់មកគំរាមកំហែងខ្លួននិងប្ដីខ្លួន ហើយពួកជើងកាងទាំងអស់នោះប្រើប្រាស់អាវុធខ្លីបំពាក់ដោយអាយកូមស្របពេលនោះអោយចាក់កាំភ្លើងមុខតូបរបស់ខ្លួននោះ គឺជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថា ៖

. ក្នុងកំណត់ហេតុស្ដាប់ចំលើយថ្ងៃទី២៥ ០២ ០២ ចំពោះមុខតំណាងអយ្យការអមតុលាការក្រុងភ្នំពេញអ្នកស្រីរស់ ចិន្តា បានឆ្លើយថាពួកជើងកាងបាននាំឈ្មោះទៅ សៀងទៅប៉ុស្តិ៍ប៉ូលីសដើម្បីប្ដឹងពីខ្លួន ។

. លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់បានឆ្លើយថា ខ្លួនពុំបានដឹងថាពួកជើងកាងប្រើប្រាស់អាវុធទេឡើយ ។

. បទល្មើសនេះ ពុំមែនជាបទល្មើសជាក់ស្ដែងទេ ហើយក្នុងការស៊ើបអង្កេតចៅក្រមស៊ើបអង្កេតពុំទាន់រកឃើញនូវភស្ដុតាងណាមួយដូចការចោទប្រកាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទេឡើយ ។

- យល់ឃើញថា ការឃុំខ្លួនឈ្មោះលីម គឹមសេងនិងឈ្មោះទៅ សៀង ពុំមែនជាការចាំបាច់ដូចដែលមានចែងក្នុងមាត្រា១៤នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទេ ពីព្រោះជនជាប់ចោទមានទីលំនៅច្បាស់លាស់ មានមុខរបរពិតប្រាកដ មិនអាចគេចវេះពីតុលាការបានទេឡើយ ។

- យល់ឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីនិងជនជាប់ចោទបានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ៤២ "គ" ចុះថ្ងៃទី០៧ ០៨ ២០០២របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងនីតិច្បាប់ហើយ ។

ហេតុ ដូ ច្នេះ

វិនិច្ឆ័យសេចក្ដីកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីនិងជនជាប់ចោទ

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ៦៨ចុះថ្ងៃទី២៣ - ៨ - ២០០២របស់អ្នកស្រីរស់ ចិន្តា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងនីតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៤២ "គ" ចុះថ្ងៃទី០៧ ០៨ ២០០២របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ខែមិថុនាឆ្នាំ ២០០៣ ។